ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកុម្ភៈ និងទិសដៅការងារខែមីនា ឆ្នាំ២០២២

នៅក្នុងខែកុម្ភៈនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម តាមបែបគន្លងប្រក្រតីភាពថ្មី លើវិស័យនៃការងារសំខាន់ៗជាច្រើន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនដោយទទួលបានលទ្ធផលសំខាន់ៗដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖

### ១- មុខងារតាមដានការអនុវត្តច្បាប់

- បានរៀបចំទីកន្លែង និងផ្តល់សេវាជូនគណៈកម្មការទី៥ព្រឹទ្ធសភា ជួបប្រជុំពិភាក្សាការងារជាមួយគណៈប្រតិភូក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងឯកឧត្តម នាយឧត្តមសេនីយ៍ **គៀត ច័ន្ទថារិទ្ធ** អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីឈ្វេងយល់អំពីវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការ នៅសាលសិក្ខាសាលាខាងត្បូង ព្រឹទ្ធសភា

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិក សមាជិកាព្រឹទ្ធសភា៖

+អញ្ជើញជួបជាមួយអាជ្ញាធរខណ្ឌ ដើម្បីឈ្វេងយល់អំពីសភាពការណ៍រួមក្នុងមូលដ្ឋាន ក្រោយការបើកប្រទេសឡើងវិញ ការងារសន្តិសុខ សណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈ និងការត្រៀមលក្ខណៈសម្រាប់ការបោះឆ្នោតឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នាពេលខាងមុខ នៅខណ្ឌកំបូល រាជធានីភ្នំពេញ

+អញ្ជើញជួបជាមួយក្រុមប្រឹក្សាឃុំ ដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មាន អំពីវឌ្ឍនភាព និងបញ្ហានានា ជុំវិញដំណើរការឆ្ពោះទៅរកការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ នាពេលខាងមុខ នៅខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443, ទូរសារ: (855 23) 211 446, E-mail: oumsarith_sgsenate@gmail.com, oumsarith_sgsenate@yahoo.com

+អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីក្តាប់នូវស្ថានការណ៍ជាក់ស្តែង ពិនិត្យតាមដានយន្តការនៃការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នៅថ្នាក់ក្រោមជាតិ ការអនុវត្តតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ អំពីបញ្ហាប្រឈម និងសំណូមពរនានា នៅខេត្តកំពង់ធំ

+អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មាន អំពីវឌ្ឍនភាព និងបញ្ហាផ្សេងៗ នៅខេត្តព្រះវិហារ

+ អញ្ជើញចូលរួមប្រជុំអន្តរក្រសួងស្តីពី វឌ្ឍនភាពនៃការពិនិត្យសិក្សា និងចងក្រងឯកសារទីតាំងដីដែលប្រជាពលរដ្ឋប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែងក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ នៅក្នុងភូមិសាស្ត្រខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ

+អញ្ជើញចូលរួមពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ និងមេភូមិ ដើម្បីឈ្វេងយល់លើការងារផ្តល់សេវារដ្ឋបាល ការងារអត្រានុកូលដ្ឋាន ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ការធ្វើសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ការកែតម្រូវអក្ខរាវិរុទ្ធក្នុងអត្រានុកូលដ្ឋាន មូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់ និងការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ព្រមទាំងបញ្ហាប្រឈម នៅសាលាស្រុកថ្មពួក ខេត្តបន្ទាយ-មានជ័យ

+អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់ពីការកសាង និងអភិវឌ្ឍហេដ្ឋារចនា-សម្ព័ន្ធបម្រើឱ្យវិស័យឱជីជលផល នៅថ្នាក់មូលដ្ឋាន នៅខេត្តពោធិ៍សាត់ និងខេត្តកោះកុងៗ

**២- មុខងារតំណាង**

- បានផ្តល់សេវា និងអមដំណើរ**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** អញ្ជើញចូលរួមដង្ហែ និងទទួលព្រះរាជដំណើររបស់**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ស្តេចយាងចូលរួមពិធីបើកព្រឹត្តិការណ៍ប្រកួតកីឡាអូឡាំពិករដូវរងារ នៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន

- បានផ្តល់សេវា និងអមដំណើរ**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុម កា អនុប្រធានទី១ ព្រឹទ្ធសភា** អញ្ជើញចុះជួបសំណេះសំណាល និងសាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាសង្កាត់ទាំង៧ ក្នុងខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

- បានផ្តល់សេវា និងអមដំណើរ**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** អញ្ជើញនាំយកទេយ្យទាន និងបច្ច័យប្រគេនព្រះសង្ឃ នៅវត្តប្រាំបីមុំ ស្ថិតក្នុងឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តមុខងារតំណាង ឆ្នាំ២០២១ និងលើកទិសដៅឆ្នាំ២០២២ របស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ និងក្រុមសមាជិកាព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា អនុប្រធានទី១ ព្រឹទ្ធសភា** នៅសាលសិក្ខាសាលាបណ្ណាល័យ ព្រឹទ្ធសភា

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ដើម្បីជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ-សង្កាត់ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈមនៃការផ្តល់សេវាសាធារណៈ គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ សម្ពោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ផ្សព្វផ្សាយអំពីវិធានការរបស់ក្រសួងសុខាភិបាលស្តីពី វិធីការពារខ្លួនពីជំងឺរាតត្បាតកូវីដ-១៩ ជាពិសេសអប់រំប្រជាពលរដ្ឋឱ្យរៀនរស់ជាមួយជំងឺកូវីដ-១៩ ព្រមទាំងបាននាំយកគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋដែលកំពុងជួបការលំបាកចំនួន១៦៩លើក នៅមូលដ្ឋានរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តរតនគិរី ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តព្រៃវែង និងខេត្តស្វាយរៀង

- បានផ្តល់សេវា និងអមដំណើរប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់របស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារទីចាត់ការចំនួន០១ខ្នង និងអគារសិក្សាថ្មីចំនួន០១ខ្នង ដែលជាអំណោយដ៏ថ្លៃថ្លារបស់ឯកឧត្តម**អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា និងជាប្រធានក្រុមការងារចុះជួយខណ្ឌជ្រោយចង្វារ និងអង្គការស្ពានកម្ពុជា-ហូឡង់ នៅសាលាបឋមសិក្សាព្រែកតាពត់ ស្ថិតក្នុងភូមិព្រែកតាពត់ សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

- ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល និងសាកសួរសុខទុក្ខអាជ្ញាធរសង្កាត់ជ្រោយចង្វារ សង្កាត់ព្រែកតាសេក និងសង្កាត់ព្រែកលៀប ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

- ឯកឧត្តមអគ្គលេខាធិការស្តីទីព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** បាននាំយកថវិកាផ្ទាល់របស់ឯកឧត្តមកិត្តិសង្គហបណ្ឌិតចំនួន ១០,០០០,០០០រៀល ឧបត្ថម្ភដល់សាលាបឋមសិក្សាអនុវត្តរាជធានី ដើម្បីកែលម្អបរិស្ថានសាលារៀន

- ឯកឧត្តមអគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល និងសាកសួរសុខទុក្ខអាជ្ញាធរសង្កាត់បាក់ខែង និងសង្កាត់កោះដាច់ ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

- បានផ្តល់សេវាជូនក្រុមការងាររបស់**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ព្រឹទ្ធសភា** អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅខេត្តត្បូងឃ្មុំ

- បានទទួលពាក្យបណ្តឹងចំនួន០៣ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន១៣ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន១៣ករណី កំពុងពិនិត្យសិក្សាចំនួន០៣ករណី ឆ្លើយបតទៅម្ចាស់បណ្តឹងចំនួន១៤ករណី និងទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នពាក់ព័ន្ធចំនួន០១ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន០៤ករណី

- បានផ្តល់សៀវភៅដែលបោះពុម្ពដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនក្រសួងការពារជាតិ និងកងរាជអាវុធហត្ថការពារព្រំដែនកម្ពុជា-ឡាវ ចំនួន៥,២១៥ក្បាល

- បានរៀបចំគ្រឿងសក្ការបូជាសម្រាប់រាប់បាត្រប្រគេនព្រះសង្ឃចំនួន៨០កញ្ចប់ ក្នុងពិធីបុណ្យមាឃបូជា

- បានធ្វើលិខិតអបអរសាទររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសដែលសម្តេចត្រូវបានជ្រើសរើសជាជ័យលាភី **ពានរង្វាន់សន្តិភាពស៊ុនហាក់ ឆ្នាំ២០២២** (SUNHAK PEACE PRIZE 2022) ពីមូលនិធិសន្តិភាពស៊ុនហាក់របស់សាធារណរដ្ឋកូរ៉េ

- បានចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចម្រើនជន្មាយុចំនួន០៨លើក

- បានធ្វើសាររំលែកទុក្ខជូនគ្រួសារសពមន្ត្រីជាន់ខ្ពស់ចំនួន០២លើក

- បានផលិតទស្សនាវដ្តីប្រចាំខែកុម្ភៈ ឆ្នាំ២០២២ ចំនួន៨០០ក្បាល។

**៣- មុខងារសហប្រតិបត្តិការអន្តរជាតិ**

- បានរៀបចំទឹកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបសវនាការ និងសម្តែងការគួរសម ជូន**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ជាមួយឯកឧត្តម **Dató Sri Ismail Sabri Bin YAAKOB** នាយករដ្ឋមន្ត្រីនៃប្រទេសម៉ាឡេស៊ី

- បានរៀបចំទឹកតែ្នង និងផ្តល់សេវាក្នុងពិធីជំនួបសម្តែងការគួរសម ជូន**ឯកឧត្តម កិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** ជាមួយប្រតិភូបេក្ខជនជ័យលាភីអាហារូបករណ៍អូស្ត្រាលីចំនួន២២នាក់

- បានរៀបចំទឹកតែ្នង និងផ្តល់សេវាក្នុងពិធីជំនួបសម្តែងការគួរសម និងពិភាក្សាការងារ ជូនសមាជិកព្រឹទ្ធសភា ជាមួយឯកអគ្គរាជទូតរដ្ឋគូវ៉ែត ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា, គណៈអភិបាលខេត្តម៉េតស(Metz) នៃសាធារណរដ្ឋបារាំង, អ្នកវិនិយោគទុនមកពីព្រះរាជាណាចក្រជប៉ុន ប្រទេសអូស្ត្រាលី និងនាយកក្រុមហ៊ុនមេត្រូ CAT

- បានរៀបចំចាត់ចែងជូនសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាការងារដើម្បីត្រៀមទទួលគណៈប្រតិភូបេសកកម្មសុច្ឆន្ទៈ នៃគណៈកម្មការនយោបាយ (APF) ដែលនឹងមកបំពេញទស្សនកិច្ចនៅកម្ពុជាកំឡុងសប្តាហ៍ទី០៣ ខែមីនា ឆ្នាំ២០២២, កិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភា ទទួលបន្ទុកសហប្រតិបត្តិការជាមួយមហាសន្និបាតសភាតំបន់អាស៊ី (APA) ស្តីពីការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងបញ្ហាផ្សេងៗ និងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នៃក្រុមសភាជាតិ (APF)

- ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអនុញ្ញាតឱ្យអគ្គទីប្រឹក្សានៃស្ថានទូតសហព័ន្ធរុស្ស៊ីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបពិភាក្សាការងារ ព្រមទាំងអញ្ជើញចូលរួមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) និងពិភាក្សាអំពីកិច្ចសហប្រតិបត្តិការនានា នៅព្រឹទ្ធសភាបារាំង និងបន្តចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នៃសមាគមអគ្គលេខាធិការប្រើប្រាស់ភាសាបារាំង (ASGPF) នៅប្រទេសសេណេហ្គាល់

- បានរៀបចំកម្មវិធីផ្សព្វផ្សាយសៀវភៅដែលផ្តល់ដោយមជ្ឈមណ្ឌលវប្បធម៌ចិន និងសមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន នៅសាលសិក្ខាសាលាខាងត្បូង ព្រឹទ្ធសភា

- បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតចិន, ស្ថានទូតឥណ្ឌា, ស្ថានទូតថៃ, ដៃគូភាគីចិន, ទីស្តីការគណៈរដ្ឋមន្ត្រី, អង្គការមូលនិធិអាស៊ី, មជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ(HRD), មជ្ឈមណ្ឌលសភាអាស៊ី(PCA), វិទ្យាស្ថានSalaCyber, វិទ្យាស្ថានDataU Academy, វិទ្យាស្ថានCamKPI Professional Academy, វិទ្យាស្ថានជាតិស្ថិតិ(NIS), វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(NIPTICT), ភ្នាក់ងារសព្ទមព័ត៌មានជាតិ(NIA), សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន, ក្រុមហ៊ុនCambodia Hosting និង

ក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ។

**៤- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

- បានសហការ និងសម្របសម្រួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ (ដូសជំរុញ) ជូនកូន ចៅរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- បានប្រជុំក្រុមប្រឹក្សាវិន័យ ដើម្បីពិនិត្យពិភាក្សាដោះស្រាយករណីមន្ត្រីនៃនាយកដ្ឋានរដ្ឋបាល នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- បានប្រជុំពិនិត្យលើសេចក្តីព្រាងកម្មវិធីផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សឆ្នាំ២០២២
- បានប្រជុំស្តីពី ការងាររដ្ឋបាល និងហិរញ្ញវត្ថុ
- បានប្រជុំផ្សព្វផ្សាយរបាយការណ៍សភាពការណ៍រួមឆ្នាំ២០២១ និងទិសដៅភារកិច្ចឆ្នាំ២០២២
- បានប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្រប នឹងដំណាក់កាលថ្មី។

***៤.១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ៖***

- បានទទួលលិខិតចូលចំនួន២៧៤ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៣៧៥ច្បាប់
- បានបាញ់ថ្នាំសម្លាប់មេរោគតាមអគារនានា ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងបានសហការជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺគ្រុនចាញ់ មកបាញ់ថ្នាំសម្លាប់សត្វមូស និងសត្វល្អិតក្នុងបរិវេណព្រឹទ្ធសភា
- បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការងាររក្សាអនាម័យ បរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ ចំណតរថយន្ត ការងារសន្តិសុខ និងសណ្តាប់ធ្នាប់ ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង
- បានបើកប្រាក់បៀវត្សប្រចាំខែកុម្ភៈ ឆ្នាំ២០២២ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានរៀបចំរបាយការណ៍ចំណាយថវិកាកម្មវិធីប្រចាំខែកុម្ភៈ ឆ្នាំ២០២២
- បានរៀបចំតារាងប្រាក់បៀវត្សប្រចាំឆ្នាំ២០២២ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានកាត់ឯកសណ្ឋានការងារជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានបើកសំណើដេញថ្លៃស្តីពី ការផ្គត់ផ្គង់ប្រេងឥន្ធនៈឆ្នាំ២០២២

- បង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

- បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗចំនួន៩០ច្បាប់ និងធ្វើប័ណ្ណសម្គាល់ខ្លួនចំនួន ២០ប័ណ្ណ

- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលត្រូវពិនិត្យ និងវាយតម្លៃដំឡើងថ្នាក់បៀវត្សប្រចាំឆ្នាំ២០២២

- បានបើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន០៨វគ្គ មានសិក្ខាកាមចូលរួមចំនួន១០៤នាក់

- បានរៀបចំពិធីបិទវគ្គបណ្តុះបណ្តាលស្តីពី នីតិហិរញ្ញវត្ថុសាធារណៈ

- បានផ្សព្វផ្សាយអាហារូបករណ៍ថ្នាក់បណ្ឌិត អនុបណ្ឌិត និងថ្នាក់បរិញ្ញាបត្រ សម្រាប់ឆ្នាំសិក្សា២០២២ ជូនដល់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានទទួលរថយន្តប្រើប្រាស់ថាមពលអគ្គិសនីចំនួន០២គ្រឿង សម្រាប់គាំពារបរិស្ថាន

- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ និងផ្កានានាចំនួន០៨បួង

- បានចាត់ចែងកម្លាំង និងប្រើប្រាស់រថយន្តបោសសម្អាតតាមដងផ្លូវ ក្នុងបរិវេណព្រឹទ្ធសភា និងនៅជាប់របងខាងមុខព្រឹទ្ធសភា

- បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក, ការបិទថ្មកំនៅតាមជញ្ជាំងអគារសាលប្រជុំពេញអង្គ, ការរៀបចំជួសជុលអាងចិញ្ចឹមត្រី, ត្រួតពិនិត្យជណ្តើរយន្ត ត្រួតពិនិត្យសត្វកណ្តៀរ, ផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម, បិទលេខកូដសម្ភារសារពើភ័ណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២២១គ្រឿង/លើក

- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែកុម្ភៈ ឆ្នាំ២០២២ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័ននានា។

### ៤.២-ការងារសេវាច្បាប់ ៖

- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០១ច្បាប់ ពីរាជរដ្ឋាភិបាល

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ ប្រកាស សេចក្តីសម្រេច សេចក្តីជូនដំណឹង របាយការណ៍ និងលិខិតផ្សេងៗចំនួន១៧៦ច្បាប់

- បានធ្វើកំណត់បង្ហាញរបាយការណ៍សវនកម្មចំនួន០៤ច្បាប់

- បានចងក្រងបញ្ជីអត្ថបទច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់តាមឆ្នាំ និងនីតិកាលនីមួយៗ។

**៤.៣-ការងារស្រាវជ្រាវ៖**

-បានផលិតឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន០១ច្បាប់

- បានសិក្សាស្រាវជ្រាវ និងធ្វើសំយោគឯកសារព័ត៌មានជាតិ និងអន្តរជាតិ តាមវិស័យចំនួន៣២អត្ថបទ

- បានផលិតព័ត៌មានច្បាប់ជាតិ និងអន្តរជាតិចំនួន២៨អត្ថបទ

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែកុម្ភៈ ឆ្នាំ២០២២ ចំនួន០២ច្បាប់។

**៤.៤-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

- បានរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi និងដាក់កម្មវិធីកម្ចាត់មេរោគ Update Files Antivirus ព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេក-វិទ្យាព័ត៌មានចំនួន៣៨គ្រឿង។ បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាចំនួន២០១ប្រធានបទ

- បានបំពាក់ឧបករណ៍អេឡិចត្រូនិចមានដូចជា កុំព្យូទ័រយួរដៃ កុំព្យូទ័រលើតុ និងIpad ជូនសមាជិកព្រឹទ្ធសភា និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៥៧គ្រឿង

- បានផលិតវីដេអូសមិទ្ធផលព្រឹទ្ធសភាចំនួន០២លើក

- បានទទួល និងរៀបចំសៀវភៅច្បាប់ ឯកសារ និងសៀវភៅតាមជំនាញផ្សេងៗចំនួន២៣២ក្បាល និងកាសែតAKPចំនួន១៣ច្បាប់ ព្រមទាំងបានបោះត្រា ចុះបញ្ជីសៀវភៅ បិទប័ណ្ណខ្ទី និងសងសៀវភៅចំនួន៨២ក្បាល

- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃចំនួន២២លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន២០លើក

- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុង Chanel Telegram ព័ត៌មានប្រចាំថ្ងៃចំនួន១,៣៧៥ប្រធានបទ

- បានប្រើប្រាស់ E-Mail ជាមធ្យោបាយសម្រាប់ដំណើរការចរន្តឯកសារផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់Zoom ប្រព័ន្ធសំឡេង

ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតខ្សែវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភាឱ្យបានលឿន ល្អ និងរលូន

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ (Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ និងច្បាប់ដែលបានធ្វើវិសោធនកម្ម និងអនុម័តរួចចំនួន៣៧លើក។

### ៤.៩-ការងារពិធីការ៖

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន១៦លើក

- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន១៥ច្បាប់

- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែកុម្ភៈ ឆ្នាំ២០២២ ចំនួន០១ច្បាប់

- បានកសាងជំនួយស្មារតី ធ្វើលិខិតអបអរសាទរ និងលិខិតថ្លែងអំណរគុណ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភាចំនួន៤៨លើក។

## II-លទ្ធផលការងារគាំទ្រលើមុខងារទាំង៥៖

- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣១៩ច្បាប់

- បានតុបតែងលម្អ តាំងពិព័រណ៍រូបភាព ធ្វើហ្វូងអក្សរ និងចងបដាចំនួន១២លើក

- បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៣៤ច្បាប់ ស្មើនឹង១២២នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន០១ច្បាប់ ស្មើនឹង០១នាក់

- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន៨១១លើក

- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៩៨សំណើ

- បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ ផ្គត់ផ្គង់សម្ភារប្រើប្រាស់ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន២០លើក មានអ្នកចូលរួមចំនួន៥៦៥នាក់

- បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន២១០លីត្រ តាមការស្នើសុំរបស់អង្គភាព

ចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានថតចម្លងឯកសារចំនួន៣,៥៣៥ច្បាប់ និងចងក្រងធ្វើជាសៀវភៅចំនួន១៦ក្បាល អស់ក្រដាសចំនួន២៣,៤៤៨សន្លឹក

- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន១១៧លើក ស្មើនឹង២៥០នាក់។ បានជួសជុល ប្តូរប្រេងម៉ាស៊ីន និងអាគុយរថយន្តចំនួន ០៧គ្រឿង

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានព្រឹទ្ធសភាចំនួន១២លើក

- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube និងFacebook ចំនួន២៥៩លើក

- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន១៩លើក។

## III-ទិសដៅការងារខែមីនា ឆ្នាំ២០២២

**-បន្តអនុវត្តវិធានការ "៣ការពារ ៣កុំ" ពាក់ម៉ាស់ ធ្វើតេស្តពេលចាំបាច់ និងវិធានការចាំបាច់ផ្សេងៗទៀត (ដាក់ឱ្យនៅដាច់ដោយឡែក រឹបត្តាឡីស័ក) ប្រឆាំងនឹងជំងឺកូវីដ-១៩ និងបន្តយកចិត្តទុកដាក់ធ្វើការងារមនុស្សធម៌ក្នុង និងក្រៅស្ថាប័នឱ្យបានទាន់ពេលវេលា៖**

+យកចិត្តទុកដាក់តាមដានសុខភាពរបស់សមាជិកព្រឹទ្ធសភា

+យកចិត្តទុកដាក់តាមដានសុខភាព លក្ខខណ្ឌការងារ និងជីវភាពទូទៅក្នុងក្របខណ្ឌស្ថាប័នទាំងមូល

+ត្រៀមបត់បែនដើម្បីប្រឈមនឹងការគំរាមកំហែងថ្មីៗ កូវីដ-១៩ ជំងឺរាតត្បាតថ្មី គ្រោះធម្មជាតិ ការប្រែប្រួលអាកាសធាតុ ផលវិបាកសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន សភាពការណ៍តំបន់ និងពិភពលោក ដូចជាអំពើភេរវកម្ម អំពើឧក្រិដ្ឋកម្ម ការវាយប្រហារ និងជំរិតខាងបច្ចេកវិទ្យាព័ត៌មាន

+បន្តយកចិត្តទុកដាក់បរិស្ថាន អនាម័យ សួនច្បារ សំរាម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បច្ចេកទេស បច្ចេកវិទ្យា អគារការិយាល័យ សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

+សមត្ថភាពប្រើប្រាស់ និងថែទាំបច្ចេកទេស គ្រប់គ្រងការប្រើប្រាស់កម្លាំង និងបច្ចេក-វិទ្យាព័ត៌មានឱ្យបានសមស្របតាមការប្រែប្រួល និងតម្រូវការថ្មី ដោយធានាបានសន្តិសុខ សុវត្ថិភាព វឌ្ឍនភាព និងនិរន្តរភាព

-បន្តប្រក្រតីភាព និងនិរន្តរភាពការងាររបស់ស្ថាប័នលើគ្រប់វិស័យ និងមុខងារទាំង៥ ក្នុងលក្ខណៈបត់បែន ទន់ភ្លន់ក្នុងសភាពការណ៍ចល័ត ដើម្បីធានាបរិមាណ និងគុណភាពការងារ។ វត្តមានមន្ត្រី បុគ្គលិកប្រចាំថ្ងៃអនុវត្តផ្អែកលើការជាក់ស្តែង "វត្តមានខ្លះ ធ្វើការពីចម្ងាយខ្លះ" តបតាមតម្រូវការ និងលក្ខណៈសម្បត្តិរបស់អង្គភាពនីមួយៗដើម្បីៈ

+ធានានិរន្តរភាព ប្រក្រតីភាព ប្រសិទ្ធភាព សុវត្ថិភាពនៃការដឹកនាំ និងគ្រប់គ្រងប្រព័ន្ធការងាររដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស ព័ត៌មាន សន្តិសុខ បច្ចេកវិទ្យា នីតិវិធី ពិធីការ ការស្រាវជ្រាវ ទំនាក់ទំនងក្នុង-ក្រៅស្ថាប័ន និងក្នុង-ក្រៅប្រទេស ព្រមទាំងជំនួយកិច្ចសហប្រតិបត្តិការនានា។

**១- មុខងារនីតិកម្ម**

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងបើកសម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤ ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការការពាររុក្ខជាតិ និងភូតគាមអនាម័យ។

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាៈ

+គណៈកម្មការទី២ អញ្ជើញចុះបេសកកម្ម នៅខេត្តព្រះសីហនុ (ថ្ងៃទី០៨-០៩ ខែមេសា ឆ្នាំ២០២២)

+ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ អញ្ជើញចុះបេសកកម្ម នៅខេត្តមណ្ឌលគិរី (ថ្ងៃទី០២-០៤ ខែមីនា ឆ្នាំ២០២២)

+ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ អញ្ជើញចុះបេសកកម្ម នៅខេត្តកំពត និងខេត្តកែប (ថ្ងៃទី២១-២៥ ខែមីនា ឆ្នាំ២០២២)។

**៣- មុខងារតំណាង**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ អញ្ជើញចូលរួមពិធីបុណ្យជាតិសំខាន់ៗ

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះទៅប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ អាជ្ញាធរដែនដី និងចុះចែកអំណោយជូនប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រមទាំងចូលរួមពិធីផ្លូវការផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

-ផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា ការងារពិធីការជាតិ និងតំបន់ កម្មវិធីជំនួប កម្មវិធីផ្លូវការ និងសាសនា ការស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ អភិវឌ្ឍស្ថាប័ន ការបណ្តុះបណ្តាលធនធានមនុស្សតាមការកំណត់ និងក្នុងលក្ខណៈបត់បែនជាការតម្រូវនៃបរិបទកូវីដ-១៩

-តាមដានបញ្ហាចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ជាមួយឥណ្ឌា និងប៉ាគីស្ថាន ការអនុវត្តកម្មវិធីវិទ្យាស្ថានក្រសួងការបរទេស មជ្ឈមណ្ឌលសភាអាស៊ី(PCA) និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី។ ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ឡើងវិញជាមួយដៃគូសំខាន់ៗរបស់មជ្ឈមណ្ឌលសភាអាស៊ី(PCA) ជាមួយរដ្ឋសភា-ព្រឹទ្ធសភាបារាំង លេខាធិការដ្ឋាន(APF) លេខាធិការដ្ឋាន(AIPA) និង(KPI) ព្រមទាំងដៃគូថ្មីមួយចំនួនទៀត (វិទ្យាស្ថានសភាឡាវ)

-ត្រៀមសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលសភាអាស៊ី(PCA) តាមការអនុវត្តកម្មវិធីបណ្តុះបណ្តាលជាបន្តបន្ទាប់

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិច សកម្មភាពច្រើន

-សហការជាមួយដៃគូសំខាន់ៗ អនុវត្តកម្មវិធីសហប្រតិបត្តិការ (PCA, ITECH, MFE, APF) និងបន្តស្វែងរកជំនួយសម្រាប់អភិវឌ្ឍស្ថាប័ន ធនធានមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងការចូលរួមមហាសន្និបាត និងវេទិកានានាក្នុងក្របខណ្ឌ (IPU, APF, AIPA...)។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

-ត្រៀមរៀបចំបែបបទស្នើសុំជំនួយពីរាជរដ្ឋាភិបាលនៃប្រទេសជាមិត្តសម្រាប់នីតិកាលថ្មីខាងមុខ

-ត្រៀមរៀបចំយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល និងគម្រោងថវិកាឆ្នាំ២០២៣

-តាមដាន និងសម្របសម្រួលជាមុនជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖ (១)គម្រោងស្នើកសាងអគារថ្មី២ខ្នង, (២)គម្រោងស្នើសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី៥

-ការបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការសម្រាប់ខែមីនា ឆ្នាំ២០២២ ឱ្យបានទាន់ពេលវេលា

-យកចិត្តទុកដាក់អនុវត្តគោលការណ៍ 3E's ដោយផ្តោតលើការងារជាអាទិភាព សំខាន់ចាំបាច់ និងបន្ទាន់បំផុត៖

+ការវិនិយោគលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងវិស័យបច្ចេកទេស គឺជាស្នូលសំខាន់នៃការអភិវឌ្ឍស្ថាប័ន និងការលើកកម្ពស់សមត្ថភាពលើគ្រប់វិស័យ ព្រមទាំងជំនាញរបស់មន្ត្រីបុគ្គលិក

+ធ្វៀតបញ្ចូលការប្រើប្រាស់គ្រឿងយន្តអគ្គិសនី និងពង្រីកការបំភ្លឺដោយថាមពលព្រះអាទិត្យ ដើម្បីថែរក្សាធម្មជាតិបៃតង កាត់បន្ថយចំណាយ និងការប្រើកម្លាំងមនុស្ស ហើយចាប់ផ្តើមអនុលោមតាមបរិបទបរិស្ថានទំនើប ដែលប្រឆាំងការប្រែប្រួលអាកាសធាតុ (ការគ្រប់គ្រងសំរាម និងផ្លាស្ទិក)

-អនុវត្តការងារដើមឆ្នាំ តាមបរិបទកូវីដ-១៩ ដោយសម្រេចឱ្យបាននូវការងារជាអាទិភាព លើកផែនការ និងកម្មវិធីការងាររបស់ស្ថាប័ន និងគ្រប់អង្គភាពឆ្នាំ២០២២

-ធ្វើសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស តម្រូវការ និងការប្រឈម

-គិតគូររៀបចំដំឡើងតាមឋានន្តរសក្តិ និងថ្នាក់ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់ឆ្នាំ២០២១-២០២២

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត បម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ការអនុវត្តផែនការបណ្តុះបណ្តាលធនធានមនុស្សតាមកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា

-ការប្រជុំពីចម្ងាយ ការធ្វើការពីចម្ងាយ និងការរៀនសូត្រពីចម្ងាយ គឺជាឧបករណ៍ថ្មី វិធីសាស្ត្រថ្មីក្នុងបរិបទកូវីដ-១៩ ហើយអាចនៅបន្តក្រោយជំងឺកូវីដ-១៩

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ និងការគ្រប់គ្រងការប្រើប្រាស់ Internet

-ទំនាក់ទំនង និងជំរុញសុំការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថានទូតចិន គម្រោងជំនួយក្នុងការសាងសង់អគារសាលប្រជុំពេញអង្គថ្មី និងបំពាក់សម្ភារមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានវិទ្យា(ICT)

-នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបន្តទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍរបស់ខ្លួន (ក្រុមហ៊ុនHuawei វិទ្យាស្ថានជាតិការទូត និងដៃគូបណ្តុះបណ្តាលនានា។ល។)

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ត្រូវបន្តសហការយ៉ាងសកម្មជាមួយភាគីចិន

-បន្តការផលិតខ្សែវីដេអូអំពីប្រវត្តិអគារព្រឹទ្ធសភាក្នុងបរិវេណវិមានរដ្ឋចំការមន។

IV-**សេចក្តីសន្និដ្ឋាន**

ក្នុងខែកុម្ភៈនេះ ក្នុងបរិបទប្រែប្រួលថ្មីនារយៈពេលចុងក្រោយ ដែលការគំរាមកំហែងដោយជំងឺកូវីដ-១៩ ប្រភេទអូមីក្រុងកើតមានឡើងកាន់តែច្រើន ដើម្បីឆ្លើយតបនឹងស្ថានភាពនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បង្កើនការយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំង និងគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ-១៩ ផងដែរ។ ទន្ទឹមនឹងនេះ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅតែខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការផ្តល់សេវាតាមគន្លងថ្មីជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនបានយ៉ាងល្អប្រសើរតាមតម្រូវការចាំបាច់ជាក់ស្តែង ប្រកបដោយភាពទទួលខុសត្រូវតាមមុខសញ្ញារៀងៗខ្លួន។ ជាពិសេសក្នុងបរិបទនៃដំណើរឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា បានផ្តោតការយកចិត្តទុកដាក់ខ្ពស់ជាអាទិភាព លើមុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង ដោយបានផ្តល់សេវាជូនគណៈកម្មការជំនាញទាំង១០ ចុះបំពេញបេសកកម្ម ជួបសវនាការការងារជាមួយក្រសួង និងស្ថាប័ននានា ព្រមទាំងអមដំណើរសមាជិកព្រឹទ្ធសភា ចូលរួមគោរពវិញ្ញាណក្ខន្ធ ចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីការអភិវឌ្ឍមូលដ្ឋាន ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ផ្សព្វផ្សាយវិធានការរបស់ក្រសួងសុខាភិបាល ជាពិសេសអប់រំប្រជាពលរដ្ឋឱ្យរៀនរស់ជាមួយជំងឺកូវីដ-១៩ និងបាននាំយកគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋដែលកំពុងជួបការលំបាក នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។ ចំពោះមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានរៀបចំ និងចាត់ចែងបានយ៉ាងល្អប្រសើរជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយគណៈប្រតិភូជាតិ និងអន្តរជាតិ ព្រមទាំងកិច្ចប្រជុំនានាប្រព្រឹត្តទៅដោយរលូន។

មន្ត្រីរាជការទាំងអស់ ត្រូវបន្តយកចិត្តទុកដាក់ចូលរួមប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩នេះ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធានការរបស់ក្រសួងសុខាភិបាលឱ្យបានម៉ត់ចត់ និងបន្តចូលរួមអនុវត្តវិធានការ "៣ការពារ ៣កុំ" ឱ្យបានល្អប្រសើរ។

ថ្ងៃ សុក្រ ២ កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២២

**អគ្គលេខាធិការស្តីទី**

ឡោក_ឆាយ